# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 90

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងអភិវឌ្ឍន៍កសិកម្មនិង ជំរុញ កំណើន សេដ្ឋកិច្ច

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 08/06/12

កាលបរិច្ឆេទបញ្ចប់គម្រោង 30/06/18

៣. ចំណាយគម្រោងសរុប $43,244,490

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

១. ទ្រព្យសម្បត្តិរបស់គ្រួសារកសិករដែលបានចូលរួមក្នុងគម្រោង កើនឡើងចំនួន២៥%

២. កាត់បន្ថយនូវកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃរបស់កុមារអាយុក្រោម៥ឆ្នាំ ពីទិន្នន័យមូលដ្ឋានចំនួន៣០% មកនៅចំនួន១០%

៣. ការប្រើប្រាស់ម្ហូបអាហារប្រចាំឆ្នាំជាមធ្យមរបស់គ្រួសារកសិករគោលដៅ កើនឡើងចំនួន២៥% ពីចំនួន៣២៤ ដុល្លារ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ដំណាំតាមរដូវៈ ស្រូវ និងផ្សេងៗ Seasonal Crop Production: Rice and other

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**តាកែវ, កណ្តាល, ព្រៃវែង, ស្វាយរៀង, កំពត,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

**«លើកកម្ពស់ផលិតភាពកសិកម្ម និងពិពិធកម្មនៃប្រភពប្រាក់ចំណូលសម្រាប់គ្រួសារនៅជនបទនៅក្នុងបណ្តាខេត្តគោលដៅ»**

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច(ប៉ាឌី) ត្រូវបានសម្របសម្រួលដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គម្រោងនេះ ត្រូវបានអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្ត រដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ អង្គការដៃគូ រួមមាន៖ SNV iDE និង FAO និងក្រុមកែលម្អទុនបង្វិល/មូលដ្ឋាន។ គម្រោងទទួលបានហិរញ្ញប្បទានពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមានការរួមបដិភាគពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ដៃគូអនុវត្តគម្រោងដែលមាន អង្គការ FAO, SNV និង iDE បានធ្វើបដិភាគថវិកាសម្រាប់ការអនុវត្តគម្រោងផងដែរ។

គម្រោង PADEE ត្រូវបានអនុវត្តនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត រួមមាន ខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ។ រយៈពេលនៃការអនុវត្តគម្រោងមានចំនួន៦ឆ្នាំ ដែលចាប់ផ្តើមនៅក្នុងឆ្នាំ ២០១២ និងបញ្ចប់នៅឆ្នាំ ២០១៧។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ការទទួលខុសត្រូវទូទៅសម្រាប់ការសម្របសម្រួលនិងគ្រប់គ្រងគម្រោងដោយអង្គភាពគាំទ្រគម្រោងរបស់ខ្លួន (Project Support Unit: PSU) ក្រសួងកិច្ចការនារី តាមរយៈអង្គភាពគាំទ្រការអនុវត្តគម្រោងរបស់ខ្លួន (Implementing Support Unit: ISU) និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាភ្នាក់ងារសម្របសម្រួលនិងអនុវត្តគម្រោងនៅថ្នាក់ជាតិ។ រដ្ឋបាលខេត្ត កំពត កណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ គឺជាភ្នាក់ងារអនុវត្ត សម្របសម្រួល និងគ្រប់គ្រងគម្រោងនៅថ្នាក់ក្រោមជាតិ។

គម្រោងអនុវត្តក្រោមសមាសភាគ៣៖

សមាសភាគទី១៖ ធ្វើឲ្យប្រសើរឡើងនូវការទទួលបាន និងប្រើប្រាស់ថវិកាពីសេវាកម្មហិរញ្ញវត្ថុ
អនុសមាសភាគ ១.១_ ការផ្ទេរទុនដោយមានលក្ខខណ្ឌដល់ក្រុម
អនុសមាសភាគ ១.២_ កសាងសមត្ថភាពក្នុងការទទួលបាននិងប្រើប្រាស់ថវិកា
អនុសមាសភាគ ១.៣_ គាំទ្រក្រុមកែលម្អទុនបង្វិលដែលមានស្រាប់។

សមាសភាគទី២ : ធ្វើឲ្យប្រសើរនូវការទទួលបានបច្ចេកទេសនិងទីផ្សារ
អនុសមាសភាគទី២.១_ គាំទ្រដល់ការច្នៃប្រឌិតក្នុងការកសាងសមត្ថភាព
អនុសមាសភាគទី២.២_ ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព
អនុសមាសភាគទី២.៣_ ការអភិវឌ្ឍ «ជំនួញជនបទខ្នាតតូច»

សមាសភាគទី៣ : ការងារសម្របសម្រួលនិងគ្រប់គ្រងគម្រោង
អនុសមាសភាគ ៣.១_ អង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អនុសមាសភាគ ៣.២_ អង្គភាពគាំទ្រអនុវត្តន៍គម្រោងនៃក្រសួងកិច្ចការនារី
អនុសមាសភាគ ៣.៣_ រដ្ឋបាលថ្នាក់ក្រោមជាតិ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

- លើកកំពស់ផលិតកម្មកសិកម្ម
- កសិករយល់ដឹងពីការប្រើប្រាស់សេវាឥណទានដោយឆ្លងកាត់វគ្គបណ្តុះបណ្តាលចំណេះដឹងហិរញ្ញវត្ថុ
- ផលិតផលកសិកម្មផ្សារភ្ជាប់ទៅនឹងទីផ្សារដោយមានការកែលម្អគុណភាពនិងការបន្ថែមតម្លៃ
- កសិករអាចគ្រប់គ្រងសហគមន៍កសិកម្មដែលផ្តួចផ្តើមដោយគម្រោងដោយខ្លួនឯង
- កសិកររៀនសូត្រនិងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមកតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- **អ្នកទទួលផលផ្ទាល់៖ ចំនួន៤៩.២០០ គ្រួសារ**
- **អ្នកទទួលផលប្រយោល៖ ចំនួន៤០.៨០០ គ្រួសារ។**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

- **គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីក្នុងការអនុវត្តគម្រោងនេះទេ។**
- **ស្ត្រីត្រូវបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងមានធនធានមនុស្សនិងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

បច្ចុប្បន្នភាពនៃការរីកចំរើនរបស់គម្រោង៖

១. ក្រុមកែលម្អទុនបង្វិលចំនួន៩៨៤ក្រុម បានទទួលទុនដែលផ្តល់ដោយគម្រោង បានទទួលការបណ្តុះបណ្តាល និងទទួលយកបច្ចេកទេសកសិកម្មថ្មីទៅអនុវត្ត មានដូចជា៖ ផលិតកម្មស្រូវ ផលិតកម្មពូជស្រូវ ផលិតកម្មសត្វ និងការចិញ្ចឹមជ្រូក ការដាំបន្លែ ការចិញ្ចឹមត្រី ការដាំឪឡឹក ការបណ្តុះផ្សិត និងសិប្បកម្ម។

២. កសិករយល់ដឹងពីការប្រើប្រាស់សេវាឥណទានដោយឆ្លងកាត់វគ្គបណ្តុះបណ្តាលចំណេះដឹងហិរញ្ញវត្ថុ (មូលដ្ឋាន និងជាន់ខ្ពស់) និងការផ្តល់ទុន។

៣. ដំណើរនៃការផ្សារភ្ជាប់ផលិតផលកសិកម្មទៅនឹងទីផ្សារ និងខ្សែចង្វាក់តម្លៃ កំពុងរៀបចំនិងអនុវត្ត។

៤. កសិករអាចរៀបចំដោយខ្លួនឯងជាក្រុមរួចជាស្រេចដើម្បីក្លាយខ្លួនជាសហគមន៍កសិកម្មដែលមានការផ្តួចផ្តើមដោយគម្រោង។

៥. កសិកររៀនសូត្រ និងចែករំលែកចំណេះដឹងនិងបទពិសោធន៍ពីគ្នាទៅវិញទៅមកតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍។

៦. កសិករទាំង៩៨៤ក្រុម បានបង្កើតជាបណ្តាញក្នុងចំណោមពួកគាត់ដើម្បីប្រត្តិការក្នុងភូមិទាំងមូល។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**អាយហ្វាត: មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2016 | | 2017 | 2018 | 2019 | 2020 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2018-2020 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 1,136.4 | 0.0 | 768.3 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 205.0 | 0.0 | 205.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 931.4 | 0.0 | 563.3 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 8,535.8 | 0.0 | 4,389.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 693.5 | 0.0 | 213.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 2,250.4 | 0.0 | 1,350.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 5,591.9 | 0.0 | 2,826.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 9,672.2 | 0.0 | 5,158.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2016 | | 2017 | 2018 | 2019 | 2020 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2018-2020 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 1,455.6 | 0.0 | 1,134.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 1,273.9 | 0.0 | 927.8 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 181.7 | 0.0 | 206.7 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 8,216.6 | 0.0 | 4,023.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| IFAD | 8,216.6 | 0.0 | 4,023.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 9,672.2 | 0.0 | 5,158.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: